Visit DTV.gov

# ការប្តូរទូរទស្សន៍ទៅជាឌីជីថល

## អ្វីដែលអ្នកត្រូវដឹងអំពីទូរទស្សន៍ឌីជីថល

**ការប្តូរទៅជាឌីជីថលនៅរដ្ឋហាវៃ**




### តើការប្តូរទូរទស្សន៍ឌីជីថល (DTV) គឺជាអ្វី ?

បច្ចុប្បន្ននេះ ស្ថានីយ៍ផ្សាយតាមរលកធាតុអាកាសមួយចំនួន កំពុងផ្សព្វផ្សាយទាំងបែបសម្រាប់ទូរទស្សន៍អាណាឡូក និងទាំងឌីជីថល ។ នៅថ្ងៃត្រង់នាថ្ងៃទី 15 ខែ មករា ឆ្នាំ 2009 ទៅ ស្ថានីយ៍ទូរទស្សន៍នឹងផ្សាយតែប្រភេទឌីជីថលប៉ុណ្ណោះ ។ ការប្តូរ DTV នឹងប៉ះពាល់ទៅលើអ្នកទាំងឡាយណាដែលមើលទូរទស្សន៍ឥតគិតថ្លៃដែលផ្សាយតាមរលកធាតុអាកាស (តាមរយៈអង់តែនលើដំបូល ឬ "ត្រចៀកទន្សាយ") ។ សម្រាប់ស្ទើរតែទាំងអស់នៃរដ្ឋហាវៃ ប្រសិនបើអ្នកមើលកម្មវិធីផ្សេងៗដែលផ្សាយតាមរលកធាតុអាកាសដោយប្រើទូរទស្សន៍អាណាឡូក អ្នកត្រូវតែចាត់វិធានការណ៍ឱ្យបានមុនថ្ងៃទី 15 ខែ មករា ឆ្នាំ 2009 ។ ប្រជាជនរស់នៅ Kaua'i នឹងមិនធ្វើការប្តូរទៅកាន់ឌីធីវីនាពេលនេះទេ ហើយគ្មានវិធានការណ៍ចាំបាច់សម្រាប់ប្រជាជនរស់នៅ Garden Isle នោះទេ ។

### ហេតុអ្វីបានជាយើងប្តូរទៅកាន់ឌីជីថល ?

ច្បាប់សហព័ន្ធតម្រូវឱ្យប្តូរ ដែលនឹងធ្វើឱ្យប្រេកង់មានភាពទូលាយសម្រាប់ទំនាក់ទំនងរបស់ប៉ូលីស អគ្គីភ័យ និងសង្គ្រោះបន្ទាន់ អនុញ្ញាតឱ្យអ្នកផ្សាយផ្តល់ឱ្យនូវកម្មវិធី ដែលមានគុណភាពរូបភាព និងសម្លេងកាន់តែច្បាស់ល្អ ហើយផ្តល់នូវជម្រើសកម្មវិធីកាន់តែច្រើន និងធ្វើឱ្យមានសេវាកម្មផ្សេងៗដែលឥតប្រើខ្សែកាន់តែមានភាពជឿនលឿនសម្រាប់អតិថិជន ។

### តើខ្ញុំគួរធ្វើអ្វី ដើម្បីត្រៀមជាស្រេច ?

អ្នកមានជម្រើសបី :

1. **ភ្ជាប់ទូរទស្សន៍អាណាឡូករបស់អ្នកនឹងប្រអប់សម្រាប់ប្តូរពីឌីជីថល ទៅអាណាឡូក** ។ ប្រអប់ប្តូរឌីជីថលទៅអាណាឡូក មាននៅតាមហាងលក់ ហើយមានតម្លៃដែលទិញតែម្តងចប់ត្រឹមតែ $40-$70 ។ ដើម្បីជួយអ្នកបង់ចំណាយសម្រាប់ការទិញប្រអប់នេះ រដ្ឋាភិបាលសហរដ្ឋអាមេរិកកំពុងផ្តល់នូវគូប៉ុង (coupons)ដែលមានតម្លៃ $40 ចំនួនពីរក្នុងមួយគ្រួសារ ។ (សូមចំណាំថា គូប៉ុងទាំងនេះ នឹងផុតកំណត់ក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីការផ្ញើតាមប្រៃសណីយ៍ និង គួរតែត្រូវបានស្នើសុំឱ្យបាននាដើមខែ ធ្នូ ឆ្នាំ 2008 ដើម្បីធានាថាមាន ការដឹកជញ្ជូនឱ្យមុនពេលាកបរិច្ឆេទប្តូរទូរទស្សន៍ទៅជាឌីជីថលរបស់រដ្ឋហាវៃ) ។ សម្រាប់ព័ត៌មានស្តីពីគូប៉ុង សូមចូលទៅកាន់ **www.DTV2009.gov** ឬទូរស័ព្ទទៅលេខ 1-888-388-2009 (ជាសម្លេង) ឬ 1-877-530-2634 (TTY) ។ បន្ថែមលើនេះទៀត អ្នកមិនចាំបាច់ត្រូវការអង់តែនថ្មីទេ ប្រសិនបើអ្នកទទួលបាននូវភាពចាប់បានច្បាស់សម្រាប់ប៉ុស្តិ៍អាណាឡូក 2-51 ដោយអង់តែនដែលមានស្រាប់របស់អ្នកហើយ ។ ឬ

2. **ទិញទូរទស្សន៍ឌីជីថល (ទូរទស្សន៍ដែលមានប្រដាប់រាវប៉ុស្តិ៍ឌីជីថលស្រាប់)** ។ អ្នកមិនចាំបាច់ត្រូវការទូរទស្សន៍ប្រភេទដែលមាន គុណភាពខ្ពស់ភ្លឺច្បាស់ [High Definition TV (HDTV)] ដើម្បីមើលការផ្សាយទូរទស្សន៍ជាឌីជីថលនោះទេ ។ អ្នកគ្រាន់តែត្រូវការទូរទស្សន៍ឌីជីថល (ឬទូរទស្សន៍អាណាឡូកដែលតភ្ជាប់ទៅនឹងប្រអប់សម្រាប់ប្តូរពីឌីជីថលទៅជាអាណាឡូក) ប៉ុណ្ណោះ ។ បន្ថែមលើនេះទៀត អ្នកមិនចាំបាច់ត្រូវការអង់តែនថ្មីទេ ប្រសិនបើអ្នកទទួលបាននូវការចាប់បានច្បាស់សម្រាប់ប៉ុស្តិ៍អាណាឡូក 2-51 ដោយអង់តែនរបស់អ្នកហើយ ។ ឬ

3. **ទិញសេវាកម្មទូរទស្សន៍បង់ប្រាក់** ។ ប្រសិនបើទូរទស្សន៍របស់អ្នកទទួលស្ថានីយ៍ផ្សព្វផ្សាយក្នុងស្រុក តាមរយៈអ្នកផ្តល់សេវាបង់ប្រាក់ដូចជាទូរទស្សន៍ខ្សែកាប ឬផ្កាយរណប វាត្រូវបានតម្លើងរួចជាស្រេចសម្រាប់ការផ្ទេរទៅកាន់ឌីធីវី ។ ក្រុមហ៊ុនខ្សែកាបមិនត្រូវបានតម្រូវឱ្យផ្ទេរ ឬប្តូរប៉ុស្តិ៍ណាមួយរបស់ពួកគេទៅកាន់ឌីជីថលនោះទេ ។ ទោះយ៉ាងណា ប្រសិនបើអ្នកមានទូរទស្សន៍អាណាឡូក ដែលមិនទទួលបានស្ថានីយ៍ផ្សាយក្នុងស្រុកតាមរយៈអ្នកផ្តល់សេវាបង់ប្រាក់របស់អ្នក អ្នកនឹងត្រូវការប្រអប់សម្រាប់ប្តូរពីឌីជីថលទៅជាអាណាឡូក ដើម្បីមើលការផ្សាយតាមឌីជីថលលើទូរទស្សន៍នោះ ។

សម្រាប់ព័ត៌មានបន្ថែម :

**1-888-CALL-FCC (Voice) DTV.gov/Hawaii 1-888-TELL-FCC (TTY)**

**ក្នុងរដ្ឋហាវៃ : 541-2389 ឬ 541-2390 ឬ អ៊ីម៉ែល HawaiiDTVtransition@fcc.gov**